# *របៀបបោះឆ្នោតក្នុងការបោះឆ្នោតបឋមរបស់រដ្ឋកាលីហ្វ័រញ៉ា ខែមីនា ឆ្នាំ 2024*

## ការត្រៀមខ្លួន

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ សូមចូលទៅកាន់គេហទំព័រ voterstatus.sos.ca.gov ដើម្បីប្រាកដថាព័ត៌មានរបស់អ្នកទាំងអស់មានភាពត្រឹមត្រូវ។ ប្រសិនបើអ្នកមិនទាន់បានចុះឈ្មោះទេ អ្នកអាចធ្វើការចុះឈ្មោះតាមអ៊ីនធឺណិតនៅ registertovote.ca.gov ឬទៅយកទម្រង់បែបបទនៅ DMV ការិយាល័យប្រៃសណីយ៍ បណ្ណាល័យ ឬការិយាល័យបោះឆ្នោតនៅខោនធីរបស់អ្នក។ អ្នកក៏អាចចុះឈ្មោះបានរហូតដល់ និងនៅថ្ងៃបោះឆ្នោត (ថ្ងៃអង្គារ ទី5 ខែមីនា)។ **ប្រសិនបើអ្នកបានធ្វើការចុះឈ្មោះត្រឹមថ្ងៃទី 20 ខែកុម្ភៈ អ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកនៅក្នុងប្រអប់សំបុត្រ។**

ប្រសិនបើអ្នកមិនបានចុះឈ្មោះជាមួយគណបក្សនយោបាយណាមួយទេ សន្លឹកឆ្នោតរបស់អ្នកនឹង**មិនមាន**បេក្ខជនប្រធានាធិបតីណាមួយទេនៅលើវា។ អ្នកអាចពិនិត្យមើលស្ថានភាពចុះឈ្មោះបោះឆ្នោតរបស់អ្នកនៅ voterstatus.sos.gov ។ ប្រសិនបើស្ថានភាពចុះឈ្មោះបោះឆ្នោតរបស់អ្នកត្រូវបានដាក់ថា "គ្មានគណបក្សណាដែលអ្នកចូលចិត្ត " អ្នកត្រូវតែះ

- ស្នើសុំសន្លឹកឆ្នោត "ឆ្លងកាត់" ឬធ្វើចុះឈ្មោះឡើងវិញជាមួយគណបក្សនយោបាយណាមួយ (ដើម្បីបោះឆ្នោតនៅក្នុងគណបក្ស Democratic, គណបក្ស Libertarian, ឬគណបក្ស American Independent )
- ធ្វើការចុះឈ្មោះឡើងវិញជាមួយគណបក្សនយោបាយមួយ (ដើម្បីបោះឆ្នោតក្នុងគណបក្សRepublican Green Peace និង គណបក្ស Freedom)

**<u>ជម្រើសទី 1 - បោះឆ្នោតតាមសំបុត្រ</u>**

អ្នកអាចប្រគល់សន្លឹកឆ្នោតតាមរយៈ**សំបុត្រ**។ ដោយមិនត្រូវការតែមប្រៃសណីយ៍ទេ! អ្នកគ្រាន់តែបំពេញសន្លឹកឆ្នោតរបស់អ្នក ដាក់វានៅក្នុងស្រោមសំបុត្រដែលបានផ្តល់អោយ ហើយចុះហត្ថលេខា កាលបរិច្ឆេទ និងបិទស្រោមសំបុត្រ។ ត្រូវប្រាកដថាវាត្រូវបានបិទភ្ជាប់មកវិញនៅមុនល្ងាចនៅថ្ងៃទី 5 ខែមីនា។

**<u>ជម្រើសទី 2 - ទម្លាក់នៅការិយាល័យ</u>**

អ្នកអាច**ទម្លាក់សន្លឹកឆ្នោតរបស់អ្នក**នៅការិយាល័យបោះឆ្នោតក្នុងខោនធីរបស់អ្នក ឬទីតាំងបោះឆ្នោតណាមួយ។ តាមខោនធីភាគច្រើនក៏មានប្រអប់ទម្លាក់សុវត្ថិភាពដែលរកបានចាប់ពីដើមខែកុម្ភៈ។ អ្នកអាចរកមើលប្រអប់ទម្លាក់សន្លឹកឆ្នោតតាមរយៈ caearlyvoting.sos.ca.gov ។

**<u>ជម្រើសទី 3 - បោះឆ្នោតដោយផ្ទាល់</u>**

ថ្ងៃបោះឆ្នោតគឺនៅ**ថ្ងៃអង្គារទី** 5 **ខែមីនា**។ ការបោះឆ្នោតនឹងបើកពីម៉ោង 7 **ព្រឹកដល់ម៉ោង** 8 **យប់**។

អ្នកអាចរកមើលកន្លែងបោះឆ្នោតរបស់អ្នកតាមរយៈ sos.ca.gov/elections/polling-place។

**មានខោនធីជាច្រើនក៏នឹងផ្តល់ជូនការបោះឆ្នោតដោយផ្ទាល់ពីថ្ងៃអង្គារ ទី** 27 **ខែកុម្ភៈ ដល់ថ្ងៃអង្គារ ទី** 5 **ខែមីនា។** សូមសាកសួរជាមួយនឹងការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក ឬរកមើលទីតាំងបោះឆ្នោតតាមរយៈ caearlyvoting.sos.ca.gov ។ ដើម្បីធ្វើឱ្យការបោះឆ្នោតដោយផ្ទាល់កាន់តែងាយស្រួល សូមយកសន្លឹកឆ្នោតដែលអ្នកបានទទួលតាមសំបុត្រទៅកាន់ទីតាំងបោះឆ្នោតរបស់អ្នក។